ASIAN VISION INSTITUTE

# 230549 – AVI Sustainable Development Goals Weekly News Digest, Issue 49

## 8th May – 14th May 2023

By: SARUN Virya (Intern, CSDS)

### World Migratory Bird Day marked in Tbong Khmum

On May 10, the Ministry of Environment observed World Migratory Bird Day in Tbong Khmum province to increase awareness of the importance of wetlands and instill in the public the spirit of conservation and birdlife protection. The theme for this year was "Water: Sustaining Birdlife," and the Boeung Kade multi-purpose area in the Kroch Chhmar region was named a protected area. Migratory birds rely largely on wetland supplies, which are under threat from human water demand, pollution, and climate change. The 1.643ha Boeung Kade multi-purpose area supports many bird species and is vital to people for irrigating farms and utilizing fishery resources. It also enhances the prestige of Tbong Khmum province.

**Source:** ***The Phnom Penh Post***

### Cambodia to receive $60 million credit from World Bank for solid waste, plastics management

The World Bank has authorized $60 million for Cambodia to help the country improve solid waste and plastics management. A three-million-dollar grant from the PROBLUE trust fund will help to fund the project. Economic development, urbanization, and tourism have resulted in a significant increase in solid waste and plastics use in Cambodia. The project will help the government strengthen institutional capacity for solid waste and plastics management, improve the performance of the private sector engaged in waste services, and improve waste fee systems in order to support improved solid waste operations that are environmentally, financially, and socially sustainable. Maryam Salim, World Bank country manager for Cambodia, expressed that the project will also help households gain better access to regular waste collection, and with increased landfill, recycling, and composting capacity, there will be positive impacts on public health, the environment, and tourism.

**Source:** ***Khmer Times***

### National Assembly approves environmental law

The National Assembly's Standing Committee on May 12 received a draft copy of new environment and natural resources laws for review and study. The code was proposed to re-define natural resource management procedures and was approved by the National Assembly (NA) Standing Committee and handed over to the Commission on Planning, Investment, Agriculture, Rural Development, Environment and Water Resources for review. The Council of Ministers – chaired by Prime Minister Hun Sen – also approved the draft code during an April 28 plenary session. The code will strengthen and improve the management of the environment, the protection, conservation and restoration of natural resources, biodiversity, ecosystem functions and sustainable living, and set a common strategic direction for environmental protection and natural resource conservation.

**Source:** ***The Phnom Penh Post***

### Breath of hope: Kingdom launches project to vastly improve air quality

To develop an emission inventory and produce an air quality control air quality data system, Cambodia has launched a two-year project, which will be institutionalised into the Ministry of Environment system,

and build a roadmap for a low-carbon transportation strategy for Siem Reap City. Danh Serey, Director General of Environmental Protection, expressed his optimism about the project and that it will be an important catalyst to improve air quality, enhance public health and protect the environment in order to achieve the 2030 Sustainable Development Goals. “The project will provide technical assistance to ensure the quality and accuracy of air quality data, data collection on air pollution emissions from the transport sector, and strengthening inventory activities, and so on,” he said.

**Source:** ***Khmer Times***

### WFP and Cambodian Agriculture Cooperative Corporation launch $3 million project to support smallholder farmers

The WFP and CACC are launching a project to improve the resilience and livelihoods of smallholder farmers in Koh Nhek, Mondulkiri, with funding from the Global Agriculture and Food Security Programme and CACC. The CACC project is designed to promote improved nutrition and gender equity through social behavior change approaches. It will build an inclusive and integrated organic food value chain and incentivize smallholder farmers, including women and indigenous population, to switch to the organic farming approach using only natural fertilizers and pesticides, coupled with other climate-smart practices. The goal is to increase the participating farmers’ incomes by up to 20%, compared to typical farm gate returns, and the farmers will be able to use the premiums earned to better safeguard against future shocks and stresses. To tackle the issues, the project will deploy social behavior change communication to influence food behaviors and gender equality in the households.

**Source:** ***Khmer Times***

**Centre for Sustainable Development Studies,**
**AVI Address**: #24, Street 566, Boeung Kok 2, Toul Kok, Phnom Penh, Cambodia
**Email**: admin@asianvision.org
**Facebook**: Asian Vision Institute
**Twitter**: Asian Vision Institute (@vision_asian)
**Telegram**: AVI Channel (https://t.me/asianvision)

## ទិវាសត្វស្លាបចំណាកស្រុកពិភពលោកប្រារព្ធនៅខេត្តត្បូងឃ្មុំ

កាលពីថ្ងៃទី១០ ខែឧសភា ក្រសួងបរិស្ថានបានប្រារព្ធទិវាសត្វស្លាបចំណាកស្រុកពិភពលោកនៅខេត្តត្បូងឃ្មុំ ដើម្បីបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃដីសើម និងផ្សព្វផ្សាយដល់សាធារណជននូវស្មារតីនៃការអភិរក្ស និងការពារសត្វស្លាប។ ប្រធានបទសម្រាប់ឆ្នាំនេះ គឺ "ទឹក ៖ និរន្តរភាពសត្វស្លាប" ហើយតំបន់ពហុបំណងបឹងកេត ក្នុងតំបន់ក្រូចឆ្មារ ត្រូវបានដាក់ឈ្មោះថាជាតំបន់ការពារ។ សត្វស្លាបដែលធ្វើចំណាកស្រុកពឹងផ្អែកភាគច្រើនលើការផ្គត់ផ្គង់ដីសើម ដែលស្ថិតនៅក្រោមការគំរាមកំហែងពីតម្រូវការទឹករបស់មនុស្ស ការបំពុល និងការប្រែប្រួលអាកាសធាតុ។ តំបន់ពហុបំណងបឹងកេត ១.៦៤៣ ហិចតា ទ្រទ្រង់នូវប្រភេទសត្វស្លាបជាច្រើន និងមានសារៈសំខាន់សម្រាប់ប្រជាជនក្នុងការស្រោចស្រពកសិដ្ឋាន និងប្រើប្រាស់ធនធានជលផលថែមទាំងលើកកំពស់កិត្យានុភាពខេត្តត្បូងឃ្មុំផងដែរ។

**ប្រភព:** [*The Phnom Penh Post*]

## កម្ពុជានឹងទទួលបានឥណទាន ៦០លានដុល្លារពីធនាគារពិភពលោក សម្រាប់ការគ្រប់គ្រងសំណល់រឹង និងប្លាស្ទិក

ធនាគារពិភពលោកបានផ្តល់ប្រាក់កម្ចីចំនួន ៦០លានដុល្លារ ដល់ប្រទេសកម្ពុជាដើម្បីជួយដល់ការកែលម្អការគ្រប់គ្រងសំណល់រឹងនិងប្លាស្ទិក។ គម្រោងនេះនឹងត្រូវបានសហការហិរញ្ញប្បទានដោយជំនួយឥតសំណងពីមូលនិធិ PROBLUE Trust ក្នុងចំនួនទឹកប្រាក់ ៣ លានដុល្លារ។ ការអភិវឌ្ឍន៍សេដ្ឋកិច្ច នគរូបនីយកម្ម និងទេសចរណ៍បានបណ្តាលឱ្យមានការកើនឡើងគួរឱ្យកត់សម្គាល់នៃការប្រើប្រាស់សំណល់រឹង និងប្លាស្ទិកនៅកម្ពុជា។ គម្រោងនេះនឹងជួយរដ្ឋាភិបាលពង្រឹងសមត្ថភាពស្ថាប័នសម្រាប់ការគ្រប់គ្រងសំណល់រឹង និងផ្លាស្ទិក ធ្វើឱ្យប្រសើរឡើងនូវការអនុវត្តរបស់វិស័យឯកជនដែលចូលរួមក្នុងប្រតិបត្តិការគ្រប់គ្រងសំណល់ ដើម្បីគាំទ្រដល់ការកែលម្អប្រតិបត្តិការសំណល់រឹងដែលមានការគិតគូរចំពោះផ្នែកបរិស្ថាន ហិរញ្ញវត្ថុ និងសង្គមប្រកបដោយនិរន្តរភាព។ Maryam Salim អ្នកគ្រប់គ្រងប្រចាំប្រទេសរបស់ធនាគារពិភពលោកប្រចាំកម្ពុជាបាន បញ្ជាក់ថា គម្រោងនេះក៏នឹងជួយគ្រួសារទទួលបានលទ្ធភាពកាន់តែប្រសើរឡើងក្នុងការទទួលបានសេវាប្រមូលសំរាមទៀងទាត់ ហើយជាមួយនឹងការកើនឡើងនូវសមត្ថភាពចាក់សំរាម ការកែច្នៃឡើងវិញ និងជីកំប៉ុស ព្រមទាំងមានផលវិជ្ជមានទៅលើសុខភាពសាធារណៈ បរិស្ថាន និងទេសចរណ៍។

ប្រភព: [*Khmer Times*]

## រដ្ឋសភាអនុម័តច្បាប់បរិស្ថាន

គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា នៅថ្ងៃទី១២ ខែឧសភា បានទទួលសេចក្តីព្រាងច្បាប់ស្តីពីបរិស្ថាន និងធនធានធម្មជាតិថ្មី ដើម្បីពិនិត្យ និងសិក្សា។ ក្រមនេះត្រូវបានស្នើឡើងដើម្បីកំណត់ឡើងវិញនូវនីតិវិធីគ្រប់គ្រងធនធានធម្មជាតិ ហើយត្រូវបានអនុម័តដោយគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា ហើយបានប្រគល់ទៅឱ្យគណៈកម្មការផែនការ ការវិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក ដើម្បីពិនិត្យ។ ទីស្តីការគណៈរដ្ឋមន្ត្រី ដែលដឹកនាំដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បានអនុម័តសេចក្តីព្រាងច្បាប់នេះផងដែរ ក្នុងសម័យប្រជុំពេញអង្គកាលពីថ្ងៃទី២៨ ខែមេសា។ ក្រមនេះនឹងពង្រឹង និងកែលម្អការគ្រប់គ្រងបរិស្ថាន ការការពារ ការអភិរក្ស និងការស្តារឡើងវិញនូវធនធានធម្មជាតិ ជីវចម្រុះ មុខងារប្រព័ន្ធអេកូឡូស៊ី

និងការរស់នៅប្រកបដោយនិរន្តរភាព និងកំណត់ទិសដៅយុទ្ធសាស្រ្តរួមសម្រាប់ការការពារបរិស្ថាន និងការអភិរក្សធនធានធម្មជាតិ។

ប្រភព: [The Phnom Penh Post]

## ដង្ហើមនៃក្តីសង្ឃឹម៖ ព្រះរាជាណាចក្រកម្ពុជា ចាប់ផ្តើមគម្រោងកែលម្អគុណភាពខ្យល់អោយកាន់តែប្រសើរ

ដើម្បីអភិវឌ្ឍសារពើភ័ណ្ឌការបំភាយ និងផលិតប្រព័ន្ធគ្រប់គ្រងគុណភាពខ្យល់ កម្ពុជាបានដាក់ឱ្យដំណើរការគម្រោងរយៈពេលពីរឆ្នាំ ដែលនឹងត្រូវដាក់បញ្ចូលទៅក្នុងប្រព័ន្ធក្រសួងបរិស្ថាន និង ផែនទីបង្ហាញផ្លូវសម្រាប់យុទ្ធសាស្រ្តដឹកជញ្ជូនកាបូនទាបសម្រាប់ក្រុងសៀមរាប។ លោក Danh Serey អគ្គនាយកនៃកិច្ចការពារបរិស្ថានបានសម្តែងសុទិដ្ឋិនិយមចំពោះគម្រោងនេះ ហើយថាវានឹងជាកាតាលីករដ៏សំខាន់ក្នុងការលើកកម្ពស់គុណភាពខ្យល់ លើកកំពស់សុខភាពសាធារណៈ និងការពារបរិស្ថាន ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ 2030។ លោកបានមានប្រសាសន៍ថា "គម្រោងនេះនឹងផ្តល់ជំនួយបច្ចេកទេសដើម្បីធានាគុណភាព និងភាពត្រឹមត្រូវនៃទិន្នន័យគុណភាពខ្យល់ ការប្រមូលទិន្នន័យស្តីពីការបំភាយខ្យល់ពុលចេញពីវិស័យដឹកជញ្ជូន និងការពង្រឹងសកម្មភាពសារពើភ័ណ្ឌជាដើម។

ប្រភព: [Khmer Times]

## WFPនិងCACCចាប់ផ្តើមគម្រោងតម្លៃ៣លានដុល្លារដើម្បីជួយកសិករខ្នាតតូច

WFP និង CACC កំពុងចាប់ផ្តើមគម្រោងធ្វើឱ្យប្រសើរឡើងនូវភាពធន់ និងជីវភាពរបស់កសិករខ្នាតតូចនៅកោះញែក ខេត្តមណ្ឌលគិរី ដោយមានមូលនិធិពីកម្មវិធីកសិកម្ម និងសន្តិសុខស្បៀងសកល និង CACC ។ គម្រោង CACC ត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់អាហារូបត្ថម្ភ និងសមភាពយេនឌ័រដែលប្រសើរឡើង តាមរយៈវិធីសាស្ត្រផ្លាស់ប្តូរអាកប្បកិរិយាសង្គម។ វានឹងបង្កើតខ្សែសង្វាក់តម្លៃអាហារសេរីរាង្គដែលរួមបញ្ចូលគ្នា និងលើកទឹកចិត្តកសិករខ្នាតតូចរួមទាំងស្រ្តី និងប្រជាជនជនជាតិដើមភាគតិចឱ្យប្តូរទៅវិធីសាស្រ្តកសិកម្មសរីរាង្គ ដោយប្រើជីធម្មជាតិ និងថ្នាំសម្លាប់សត្វល្អិត រួមជាមួយការអនុវត្តដ៏កសិកម្មឆ្លាតវៃដើម្បីបង្កើនភាពធន់ទៅនឹងបម្រែបម្រួលអាកាសធាតុ។ គោលដៅគឺដើម្បីបង្កើនប្រាក់ចំណូលរបស់កសិករដែលចូលរួមរហូតដល់ 20% ហើយកសិករនឹងអាចប្រើប្រាស់ចំណូលដែលរកបានដើម្បីការពារកាន់តែប្រសើរឡើងពីផលប៉ះពាល់ និងភាពតានតឹងនាពេលអនាគត។ ដើម្បីដោះស្រាយបញ្ហា គម្រោងនេះនឹងដាក់ពង្រាយការទំនាក់ទំនងផ្លាស់ប្តូរអាកប្បកិរិយាសង្គម ដើម្បីជះឥទ្ធិពលលើឥរិយាបថម្ហូបអាហារ និងសមភាពយេនឌ័រនៅក្នុងគ្រួសារ។

ប្រភព: [Khmer Times]

**មជ្ឈមណ្ឌលនៃការសិក្សាអភិវឌ្ឍន៍ប្រកបដោយចីរភាព**
អាសយដ្ឋាន: ផ្ទះលេខ២៤ ផ្លូវ៥៦៦ សង្កាត់ បឹងកក់២ ខណ្ឌ ទួលគោក រាជធានី ភ្នំពេញ
**Email**: admin@asianvision.org
**Facebook**: Asian Vision Institute
**Twitter**: Asian Vision Institute (@vision_asian)
**Telegram**: AVI Channel (https://t.me/asianvision)